


**"យើងទាំងអស់គ្នាត្រូវការសិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិក្នុងការជ្រើសរើស"**
**សង្គមស៊ីវិលសូមសំណូមពរដល់រាជរដ្ឋាភិបាល សូមមេត្តារក្សាសេរីភាពសារព័ត៌មាន**

ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៣៖ យើងខ្ញុំ ជាអង្គការសង្គមស៊ីវិលមានរាយនាមដូចខាងក្រោម សូមស្វាគមន៍ដល់សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងការលុបចោលនូវវិធានការណ៍ដ៏មានការភ្ញាក់ផ្អើល ដែលបានចេញកាលពីសប្តាហ៍មុន ក្នុងការត្រួតពិនិត្យចាប់ពិរុទ្ធប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុកនៅក្នុងប្រទេសកម្ពុជា នៅមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ហើយយើងខ្ញុំ ក៏សូមមិនទទួលយកនូវសេចក្តីសម្រេច ក្នុងការអនុវត្តវិធានការត្រួតពិនិត្យចាប់ពិរុទ្ធបែបនេះ កាលពីពេលមុន។ ក៏ប៉ុន្តែយើងខ្ញុំ នៅតែមានការព្រួយបារម្ភយ៉ាងខ្លាំងពីការរឹតត្បិត ដែលនៅតែមាន ដោយហាមឃាត់ទៅលើការរាយការណ៍ព័ត៌មានតាមវិទ្យុបរទេសមួយចំនួនអំពីការបោះឆ្នោត ក្នុងរយៈពេល ៥ថ្ងៃ មុនថ្ងៃបោះឆ្នោត។

យើងខ្ញុំ សូមមិនទទួលយកបម្រាមនេះ ហើយសំណូមពរដល់រាជរដ្ឋាភិបាល សូមលោកមេត្តាលុបចោលនូវការរឹតត្បិតលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ក្នុងអំឡុងពេលមុនការបោះឆ្នោតដ៏សំខាន់នេះ។ យើងខ្ញុំ ក៏សូមអំពាវនាវផងដែរដល់រាជរដ្ឋាភិបាល សូមលោកមេត្តាធានាថានឹងមិនមានការរឹតត្បិតដោយការត្រួតពិនិត្យចាប់ពិរុទ្ធតាមប្រព័ន្ធរលកធាតុអាកាស ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មានណាមួយដដែលផ្សេងទៀតទេ រួមទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គមតាមប្រព័ន្ធអ៊ិនធើណេតផង។

បទបញ្ជាដោយឡែកពីគ្នាចំនួន ២ ដែលមានវិសាលភាពខ្លាំងក្លា ត្រូវបានចេញដោយក្រសួងព័ត៌មាន កាលពី ២សប្តាហ៍មុន ដោយធ្វើការហាមឃាត់ស្ថានីយ៍វិទ្យុ FM ក្នុងការមិនឲ្យផ្សាយបន្តពីកម្មវិធីវិទ្យុបរទេសជាខេមរភាសា និងរាយការណ៍ពីជនបរទេសដែលចូលរួមក្នុងយុទ្ធនា

ការឃោសនាបោះឆ្នោត។ ពីដំបូងបម្រាមនេះ ត្រូវបានដាក់ឲ្យអនុវត្តរហូតដល់ថ្ងៃបោះឆ្នោត ប៉ុន្តែក្រោយមកត្រូវបានលុបចោលវិញនៅថ្ងៃទី២៩ ខែមិថុនា។

បទបញ្ជាដំបូង ដែលត្រូវបានចេញនៅថ្ងៃទី២១ ខែមិថុនា បានហាមឃាត់គ្រប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ ក្នុងការមិនឲ្យផ្សាយបន្តពីវិទ្យុបរទេស ទាក់ទងនឹងការរាយការណ៍អំពីការស្ទាបស្ទង់មតិ ស្រាវជ្រាវ និងលទ្ធផលនៃការបោះឆ្នោត ក្នុងអំឡុងពេល ៥ថ្ងៃ មុនថ្ងៃបោះឆ្នោត។ បម្រាមនេះ នៅតែត្រូវអនុវត្ត និងចូលជាធរមានចាប់ពីថ្ងៃទី២៣ ខែកក្កដា។

លោក ប៉ា ងួនទៀង នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលកម្ពុជាសម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌-មានឯករាជ្យ បានមានប្រសាសន៍ថា៖ "បម្រាមដែលចុះហត្ថលេខាថ្ងៃទី២១ ដែលផ្តោតទៅលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរទេស បង្ហាញនូវបំណងពិតប្រាកដក្នុងការកំណត់ដែនកំនត់ក្នុងការទទួលបានព័ត៌មានពីប្រភពព័ត៌មានឯករាជ្យរបស់ប្រជាពលរដ្ឋកម្ពុជា ដែលប្រភពទាំងនោះអាចនឹងរំខានដល់គណបក្សកាន់អំណាច។

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានខ្មែរក្នុងស្រុកមួយចំនួន មិនសូវមានសេរីភាពក្នុងការរាយការណ៍ព័ត៌មានដែលងាយប៉ះពាល់ ដូចដែលប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរទេសរាយការណ៍នោះទេ ដោយសារភាពងាយរងគ្រោះរបស់អ្នកទាំងនោះ ពីការគម្រាមកំហែងដោយប្រព័ន្ធតុលាការនៅក្នុងស្រុក។ ដែលនេះអាចធ្វើឲ្យមានការត្រួតពិនិត្យចាប់ពិរុទ្ធដោយខ្លួនឯង។ ម្ចាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុកមួយចំនួន ត្រូវបានគ្រប់គ្រងដោយគណបក្សកាន់អំណាច ហើយបណ្តាញទូរទស្សន៍ ត្រូវបានគ្រប់គ្រងដោយគណបក្សកាន់អំណាច។

លោក វ៉ន ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានមានប្រសាសន៍ថា៖ "នេះគឺជាទម្រង់នៃការត្រួតពិនិត្យចាប់ពិរុទ្ធរបស់អាជ្ញាធររដ្ឋដែលមិនប្រក្រតី និងផ្ទុយនឹងលទ្ធិប្រជាធិបតេយ្យ"។ លោកបានបន្តថា៖ "បម្រាមនេះកើតចំពេលដែលប្រជាពលរដ្ឋកម្ពុជា កំពុងត្រូវការព័ត៌មានបំផុតពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យ។ ផ្ទុយមកវិញ អ្នកទាំងនោះអាចត្រឹមតែបានទទួលបានព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលគាំទ្រអាជ្ញាធរតែប៉ុណ្ណោះ"។

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្សលីកាដូ បានមានប្រសាសន៍ថា៖ "ប្រជាពលរដ្ឋមួយចំនួន ស្ថិតក្នុងភាពមិនច្បាស់លាស់ថាតើការបោះឆ្នោតខាងមុខ នឹងប្រព្រឹត្តទៅដោយសេរី និងយុត្តិធម៌ឬទេ (មានបញ្ហាជាច្រើន រាប់ចាប់ពីកំហុសក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ដល់វិធីក្នុងការបំភិតបំភ័យ ហើយរហូតដល់វិធីក្នុងការវាយប្រហារផ្ទាល់ខ្លួនមួយចំនួនមកលើគណបក្សប្រឆាំង"។ លោកស្រីបានមានប្រសាសន៍បន្តទៀតថា៖ "ប៉ុន្តែការព្យាយាមទាំងនេះ ក្នុងការត្រួតពិនិត្យចាប់ពិរុទ្ធលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរទេសឯក

រាជ្យ អាចបង្ហាញថាអាជ្ញាធររដ្ឋមិនសូវបានយកចិត្តទុកដាក់ អំពីគោលការណ៍យុត្តិធម៌ និងការធ្វើឲ្យមានភាពស្មើគ្នានោះទេ”។

យើងខ្ញុំ ជាអង្គការសង្គមស៊ីវិលមានរាយនាមដូចខាងក្រោម សូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមលោកមេត្តា ចាត់វិធានការជាក់លាក់ ក្នុងការធានាឲ្យមានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដោយសេរី និងយុត្តិធម៌ នៅក្នុងរយៈពេលមុនការបោះឆ្នោតនាថ្ងៃទី២៨ ខែកក្កដាខាងមុខនេះ។ ជាពិសេស យើងខ្ញុំ សូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមលោកមេត្តា៖

១. លុបចោលនូវបទបញ្ជាថ្ងៃទី២១ ដែលហាមឃាត់ការរាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរទេស ដែលទាក់ទងនឹង ការស្ទាបស្ទង់មតិ ការស្រាវជ្រាវ និងលទ្ធផលនៃការស្ទាបស្ទង់មតិអំពីការបោះឆ្នោត ក្នុងរយៈពេល ៥ថ្ងៃ មុនថ្ងៃបោះឆ្នោត
២. បញ្ឈប់ការត្រួតពិនិត្យចាប់ពិរុទ្ធលើប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ឬ/និង បិទប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន នៅមុន និងក្នុងថ្ងៃបោះឆ្នោត តទៅទៀត
៣. បញ្ឈប់ការចេញបទបញ្ជាត្រួតពិនិត្យចាប់ពិរុទ្ធដោយផ្ទាល់ ឬប្រយោល ទៅលើប្រព័ន្ធអ៊ិនធើណេត រួមទាំងការបិទដោយផ្នែក ដែលត្រូវបានធ្វើឡើងដើម្បីកម្រិតការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសង្គម និង/ឬ គេហទំព័រ ដែលមានសេចក្តីរាយការណ៍ព័ត៌មានរបស់បរទេស ឬសេចក្តីរាយការណ៍ព័ត៌មានទូទៅដែលអាចប៉ះពាល់ដល់គណបក្សកាន់អំណាច
៤. អនុញ្ញាតឲ្យបើក និងធានាឲ្យមានរយៈពេលផ្សាយតាមបណ្តាញទូរទស្សន៍ស្មើគ្នាសម្រាប់គ្រប់គណបក្សទាំងអស់។

អង្គការសង្គមស៊ីវិល ដែលគាំទ្រសេចក្តីថ្លែងការណ៍នេះ មានរាយនាមដូចខាងក្រោមនេះ៖

សហគមន៍បឹងកក់ (BKL)
សហគមន៍បុរីកីឡា (BK)
មជ្ឈមណ្ឌលកម្ពុជាសម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯករាជ្យ (CCIM)
សហភាពសហជីពកម្ពុជា (CCU)
សហព័ន្ធសហជីពកម្មករចំនីអាហារ និងសេវាកម្មកម្ពុជា (CFSWF)
សមាគមមន្ត្រីរាជការកម្ពុជា (CICA)
សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
មណ្ឌលអភិវឌ្ឍន៍កម្មករកម្ពុជា (CWCD)
បណ្តាញយុវជនកម្ពុជា (CYN)
សម្ព័ន្ធសហគមន៍កសិករកម្ពុជា (CCFC)
មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC)

បណ្តាញកសាងសន្តិភាពសហគមន៍ (CPN)
សមធម៌កម្ពុជា (EC)
សមាគមអភិវឌ្ឍន៍កសិករ (FDA)
សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
លីកាដូ កាណាដា (LC)
គណៈកម្មាធិការអព្យាក្រិត និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (NICFEC)
សកម្មភាពប្រជាជនដើម្បីការផ្លាស់ប្តូរ (PAC)
សមាគមផាងត្នោត (STT)
គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)
សហព័ន្ធសហជីពវិស័យទេសចរណ៍សេវាកម្មកម្ពុជា (CTSWF)
សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC)
វិទ្យាស្ថានជាតិប្រជាធិបតេយ្យសំរាប់កិច្ចការអន្តរជាតិ (NDI)
សហគមន៍ថ្មគោល




**<u>We All Need Voices and Choices: Civil Society Urges Government to Keep Media Free</u>**

July 2, 2013 - We, the undersigned civil society organizations, welcome the government's decision to rescind shocking measures issued last week to censor Cambodia's local news media in the final weeks before the July 28 National Assembly elections, and condemn the decision ever to implement such measures. We remain deeply concerned about an order to ban foreign news reporting of election polling which will come into force five days before the vote.

We condemn this ban in the strongest possible terms and urge the government to remove all restrictions on the news media during this critical pre-election period. We also call for the government to guarantee

that it will not repeat its attempts to censor the airwaves or any other media, including social media on the internet.

The more expansive of two separate orders issued by the Ministry of Information in the past two weeks prohibited FM radio stations from broadcasting foreign news programs in Khmer and from reporting on foreigners playing any role in the campaign. It was initially designed to last through election day, but was revoked on June 29.

An earlier order, issued on June 21, bans all media from broadcasting foreign media reports regarding opinion polls, surveys and election results. This ban remains in place, and will take effect on July 23, five days before election day.

"The June 21 ban's focus on foreign media indicates that its true purpose is to limit Cambodians' access to independent media sources that might be critical of the ruling Cambodian People's Party (CPP)," said Pa Ngoun Teang, head of the Cambodian Center for Independent Media (CCIM).

Local Khmer media are not as free to report on sensitive issues as their foreign counterparts, in part due to their vulnerability to domestic judicial threats. This can result in self-censorship. Ownership of local media is also dominated by the ruling party and television networks are entirely controlled by the ruling party.

"This is censorship by the government in the most oppressive and undemocratic form," said Vorn Pao, president of the Independent Democracy of Informal Economy Association (IDEA). "And it's going to hit at a time when Cambodians need information from independent news outlets the most. Instead, they will only have access to pro-government, pro-CPP sources."

"Few people are under the illusion that this election will be free and fair – there are simply too many problems, from the flawed voters' list, to the intimidation tactics, to the relentless personal attacks on the opposition," said Dr. Pung Chhiv Kek, president of the Cambodian League for the Promotion & Defense of Human Rights (LICADHO). "But these attempts at directly censoring independent foreign media reports suggest that the government doesn't even care about making it *look* fair and balanced."

We, the undersigned civil society organizations, call upon the government to take specific steps to ensure a free and fair media in the run-up to the July 28 elections. Specifically, we call for the government to:

1. Immediately revoke the June 21 order banning foreign media reports regarding opinion polls, surveys and election results beginning five days before election day;
2. Refrain from further media censorship and/or media shutdowns prior to and on election day;
3. Refrain from ordering direct or indirect censorship of the internet, including partial blockages designed to limit access to social media and/or websites containing foreign news reports or news reports which may be critical of the ruling party;
4. Open up and ensure meaningful television airtime for all parties.

The following civil society groups endorse this joint media statement:

Boeung Kak Lake Community (BKL)
Borei Keila Community (BK)
Cambodian Center for Independent Media (CCIM)
Cambodian Confederation Unions (CCU)
Cambodian Food and Service Worker Federation (CFSWF)
Cambodia's Independent Civil-Servants Association (CICA)
Cambodian League for the Promotion and Defense of Human Rights (LICADHO)
Cambodian Worker Center for Development (CWCD)
Cambodian Youth Network (CYN)
Coalition of Cambodian Farmer Community (CCFC)
Community Legal Education Centre (CLEC)
Community Peace-Building Network (CPN)
Equitable Cambodia (EC)
Farmer Development Association (FDA)
Independent Democracy of Informal Economy Association (IDEA)
LICADHO Canada (LC)
Neutral and Impartial Committee for Free and Fair Election in Cambodia (NICFEC)
People's Action for Change (PAC)
Sahmakum Teang Tnaut (STT)
The Cambodian NGO Committee on CEDAW (NGO-CEDAW)
The Cambodian Tourism and Service Workers Federation (CTSWF)
The Building and Wood Workers Trade Union Federation of Cambodia (BWTUC)
The National Democratic Institute (NDI)
Thmor Kol Community